សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខ៖ ០០៥៦/១៥ ស.អ.ក

# ប្រកាស
# ស្តីពី
## ការបង្កើតគណៈកម្មាធិការ ទទួលបន្ទុកការងារស្រូវពូជ និង ជំរុញផលិតកម្មជាំជុះ
## (Executive Committee for Seed and Production)

## សហព័ន្ធស្រូវអង្ករកម្ពុជា

- បានឃើញនៅអនុក្រឹត្យ ស្តីពី "**ការទទួលស្គាល់សហព័ន្ធស្រូវអង្ករ**" លេខ **២២៨** អនក្រ.បក ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៥ ដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាត កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់ របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១**.

បង្កើតគណៈកម្មធិការទទួលបន្ទុកដោះស្រាយ ការងារផលិតកម្មជាំជុះនិងការកែច្នៃ (Farming & Milling Productivity Executive Committee) ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. លោកឧកញ៉ា **វង្ស ប៊ុនហេង** (ប្រធានក្រុមហ៊ុន VBH) | ប្រធាន |
| ២. លោក **សំអាត វាសនា** (តំណាងសហគមកសិករ) | អនុប្រធាន |
| ៣. លោក **ឈុន ធំ** (រោងម៉ាស៊ីន ឈុនធំ) | អនុប្រធាន |
| ៤. លោក **ឈិត ប៊ុនថន** (រោងម៉ាស៊ីន ឈិតប៊ុនថន) | សមាជិក |
| ៥. លោក **រិន សីហា** (អ្នកចាត់ការទូទៅ Kharma Rice Limited) | សមាជិក |
| ៦. លោក **វិញ ជាង** (រោងម៉ាស៊ីន NKL) | សមាជិក |
| ៧. លោក **អ៊ិត វិជិត** (ទីប្រឹក្សាសហព័ន្ធស្រូវអង្ករកម្ពុជា) | សមាជិក |
| ៨. លោក **តាំង ឈុនងី** (នាយកក្រុមហ៊ុន សម្បត្តិវឌ្ឍនៈ) | សមាជិក |
| ៩. លោក **កែវ សុខា** (តំណាងសហព័ន្ធកសិករ FAEC) | សមាជិក |
| ១០. លោក **យឹម បិយ** (ប្រធានសហគមន៍ Farmer and Water Net) | សមាជិក |
| ១១. លោក **សាក់ ជឿន** (ប្រធានក្រុមហ៊ុន AQUIP Seed) | សមាជិក |
| ១២. លោក **ពៅ ណម** (រោងម៉ាស៊ីនពៅ ណម) | សមាជិក |
| ១៣. លោក **សឹម សាធ** (តំណាងក្រុមហ៊ុន Apsara Rice) | សមាជិក |



#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

១៤. លោក **ស៊ូ សាវ៉ន** (តំណាងសេដាក់) សមាជិក

១៥. លោក **យ៉ាន់ ពេជ្យ** (មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា) សមាជិក

១៦. លោក **ហ៊ឹម ខទៀត** (មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា) សមាជិក

១៧. លោក **ផង់ ផល្លា** (មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា) លេខាធិការ

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការ នៅក្នុងក្របខ័ណ្ឌដែលមានចែង នៅក្នុងផែនការសកម្មភាព ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ តាមការងារដូចខាងក្រោម៖

- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ធ្វើការរៀបចំយុទ្ធសាស្ត្រ និងអនុវត្ត កំណត់លើប្រភេទពូជស្រូវ ដែលឆ្លើយតបតាមតម្រូវការទីផ្សារ និងយីហោអង្ករកម្ពុជា សំរាប់ជំរុញផ្សព្វផ្សាយដល់ប្រជាកសិករ និងការដាំដុះ។
- កំណត់នូវយុទ្ធសាស្ត្រ ទិសដៅការងារពូជស្រូវ ថ្នាំសំលាប់សត្វល្អិត ជី និង ការងារក្សេសាស្ត្រ។
- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ក្នុងការចរចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវកិច្ចប្រតិបត្តិការកៀងគររកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជំរុញ ការផ្សព្វផ្សាយ ការងារកិច្ចសន្យាកសិកម្ម (Contract Farming) ការងារអប់រំ ការចងក្រងសហគមន៍កសិករ និងកម្មវិធីនានា ដែលជួយដល់និរន្តភាពលើការអនុវត្តការដាំដុះ បច្ចេកទេសដាំដុះរបស់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងសន្តិសុខស្បៀងក្នុងប្រទេស។
- គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ទៀតទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើរសុំដល់ក្រុមប្រឹក្សាភិបាលឲ្យអនុញ្ញាតសម្រេចជាមុនសិន។
- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

**ប្រការ៣.**

ក្រុមប្រឹក្សាភិបាល សមាជិក សមាជិកា លេខាធិការដ្ឋាន ស.អ.ក និងការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៥

**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

**សុខ ពុទ្ធិវុធ**

<u>ចម្លងជូន៖</u>

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- គម្រោងពាណិជ្ជកម្មស្រូវនៅកម្ពុជា របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដៃគូអភិវឌ្ឍន៍ IFC, AFD
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ